សុវត្ថិភាពសម្រាប់ពេលជិះកង់

# តើថ្ងៃនេះអ្នកបានអោបក្បាលរបស់អ្នកឬទេ? ចូរពាក់មួកសុវត្ថិភាព។



The Children's Hospital *of* Philadelphia®

Hope lives here.

# កង់បណ្តាលឲ្យក្មេងមានរបួសច្រើនជាងរបស់ប្រើប្រាស់ទាំងអស់ លើកលែងតែរថយន្ត។

- សូមមើលឲ្យច្បាស់ថា កូនរបស់អ្នកពាក់មួកសុវត្ថិភាពរាល់ពេលជិះកង់ ជិះស្បែកជើងស្កេត និងក្តារស្កេត។
- មុនពេលទៅទិញមួកសុវត្ថិភាព ត្រូវវាស់ក្បាលកូនរបស់អ្នកសិន។ បន្ទាប់មកទិញមួកសុវត្ថិភាពដែលល្មមក្បាល។
- ធ្វើឲ្យច្បាស់ថា កូនពាក់មួកសុវត្ថិភាពត្រូវតាមរបៀប មួកសុវត្ថិភាពដែលរលុងប្រហែលជាមិនអាចការពារក្បាលកូនបានទេ ពេលដួល។
- មួកសុវត្ថិភាពត្រូវពាក់ចំកណ្តាលក្បាលខាងលើ កុំឲ្យវៀចទៅមុខ ទៅក្រោយ ឬទៅចំហៀង។
- រឹតខ្សែរឹតក្រោមចង្កាឲ្យតឹង។
- ធ្វើឲ្យច្បាស់ថា កូនរបស់អ្នកជិះកង់ដែលត្រូវតាមទំហំ។
- ពិនិត្យកង់កូនរបស់អ្នក ដើម្បីឲ្យដឹងថាអ្វីៗទាំងអស់នៅល្អ។ ការពិនិត្យនេះ រួមទាំង ហ្វ្រាំង ច្រវាក់ ចង្កូត និងកែប ដើម្បីឲ្យច្បាស់ថា ពួកវាដំណើរការល្អ។



## បង្រៀនកូនរបស់អ្នកនូវវិន័យទាំងនេះ:

- ជិះកង់ស្របតាមចរាចរណ៍ នៅខាងស្តាំដៃបំផុតនៃថ្នល់។
- ពេលបត់ លើកដៃជាសញ្ញា។
- បណ្តើរកង់ នៅលើផ្លូវដែលមនុស្សដើរកាត់។
- ជិះលើបន្ទាត់ សម្រាប់ជិះកង់។
- ប្រើកញ្ចក់ចាំងភ្លើងនៅលើកង់របស់អ្នក។
- ស្លៀកពាក់ពណ៌លេច ដើម្បីឲ្យអ្នកដទៃទៀត និងអ្នកបើករថយន្តអាចមើលអ្នកឃើញ។

កម្មវិធីការពារមិនឲ្យមានរបួស Kohl
(Kohl's Injury Prevention Program)

The Children's Hospital *of* Philadelphia®

Hope lives here.

©2011 មន្ទីរពេទ្យកុមារក្រុងហ្វីឡាដែលហ្វៀ (The Children's Hospital of Philadelphia) រក្សាសិទ្ធិគ្រប់យ៉ាង។ 4721/NP/04-11

សម្រាប់ព័ត៌មានបន្ថែមអំពីការរក្សាសុវត្ថិភាពកូនរបស់អ្នក និងពិធីផ្សេងៗទៀតសម្រាប់ក្រុមគ្រួសារ សូមមើល www.chop.edu/childsafety.

Committed to Kids' Health and Education